**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលអនុក្រឹត្យលេខ ៥២ អនក្រ.បក
## ស្តីពី
## ការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ២០០៧
-ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។
-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**មាត្រា ១** : មាត្រា២ នៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានកែប្រែដូចតទៅៈ

**មាត្រា២ថ្មី**: អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញដឹកនាំដោយអគ្គលេខាធិការមួយរូប អគ្គលេខាធិការរងមួយចំនួនជាអ្នកជំនួយការ នៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការដឹកនាំបញ្ជាការងាររដ្ឋបាលរបស់

www.pheakdeylaw.com

ក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការអាចទទួលសិទ្ធិពីប្រធានដើម្បីចុះហត្ថលេខាលើលិខិតឬសេចក្តីសម្រេចរដ្ឋបាល។ អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច១០ឆ្នាំហើយដែលមិនមែនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងមិនមែនជាអ្នកដឹកនាំក្នុងគណបក្សណាមួយ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com